# ព័ត៌មានលម្អិតអំពីអត្ថប្រយោជន៍សុខភាពធ្មេញ

## 2024

ឯកសារនេះផ្តល់ជូនអ្នកនូវព័ត៌មានលម្អិតបន្ថែមអំពីអត្ថប្រយោជន៍សុខភាពធ្មេញបន្ថែម ដែលត្រូវបានធានារ៉ាប់រងនៅក្រោមគម្រោងរបស់យើង។ សម្រាប់ព័ត៌មានបន្ថែមអំពីឯកសារនេះ ឬអំពីអត្ថប្រយោជន៍សុខភាពធ្មេញរបស់អ្នក សូមទាក់ទងទៅផ្នែកបម្រើសេវាសមាជិកតាមលេខទូរសព្ទ ឬអាសយដ្ឋាន ដែលបង្ហាញនៅលើក្របខាងក្រោយនៃឯកសារ *ភស្តុតាងនៃការធានារ៉ាប់រង* ឬនៅលើបណ្ណសម្គាល់សមាជិករបស់អ្នក។

*ព័ត៌មានលម្អិតអំពីអត្ថប្រយោជន៍សុខភាពធ្មេញ*នេះអនុវត្តចំពោះកញ្ចប់អត្ថប្រយោជន៍របស់គម្រោង ដែលបង្ហាញខាងក្រោម។ កញ្ចប់អត្ថប្រយោជន៍របស់គម្រោងមាននៅលើក្របរបស់ឯកសារ *ភស្តុតាងនៃ ការធានារ៉ាប់រង*នៅជ្រុងខាងស្តាំ ផ្នែកខាងក្រោម។

| រដ្ឋ | កញ្ចប់អត្ថប្រយោជន៍របស់គម្រោង | ឈ្មោះគម្រោង |
|---|---|---|
| CA | H3561001000 | Wellcare Dual Liberty (HMO D-SNP) |
| CA | H3561008000 | Wellcare Dual Align (HMO D-SNP) |
| CA | H3561009000 | Wellcare Dual Liberty (HMO D-SNP) |

[ទំព័រនេះត្រូវបានទុកឱ្យនៅទំនេរដោយចេតនា]

[ទំព័រនេះត្រូវបានទុកឱ្យនៅទំនេរដោយចេតនា]

[ទំព័រនេះត្រូវបានទុកឱ្យនៅទំនេរដោយចេតនា]

**អត្ថប្រយោជន៍សុខភាពធ្មេញដែលត្រូវបានធានារ៉ាប់រង៖** គម្រោងរបស់យើងចុះកិច្ចសន្យាជាមួយនឹង Delta Dental of California ដើម្បីគ្រប់គ្រងអត្ថប្រយោជន៍សុខភាពធ្មេញដែលត្រូវបានធានារ៉ាប់រង ដូចមានពិពណ៌នាខាងក្រោមនេះ។ សូមមើល *ភស្តុតាងនៃការធានារ៉ាប់រង* ឆ្នាំ 2024 សម្រាប់ការចែករំលែកថ្លៃចំណាយដែលត្រូវអនុវត្តតាមណាមួយ។ នីតិវិធីព្យាបាលធ្មេញដែលបានចុះបញ្ជី ដែលមិនត្រូវបានរ៉ាប់រងនៅក្រោមគម្រោងរបស់យើង អាចជាអត្ថប្រយោជន៍ ដែលមានការរ៉ាប់រងនៅក្រោមអត្ថប្រយោជន៍ថ្នាក់រដ្ឋរបស់ Denti-Cal សម្រាប់សមាជិក។ សូមពិនិត្យមើលអត្ថប្រយោជន៍ដែលមានការធានារ៉ាប់រងនៅក្រោមគម្រោង Denti-Cal ផងដែរ។

អ្នកត្រូវតែទៅជួបអ្នកផ្តល់សេវាដែលចូលរួមក្នុងគម្រោង ដែលត្រូវបានចាត់តាំងមកឱ្យអ្នក ដើម្បីទទួលបានសេវាកម្មដែលត្រូវបានធានារ៉ាប់រង លើកលែងតែសេវាកម្មសុខភាពធ្មេញក្នុងភាពអាសន្ន ឬសេវាដែលផ្តល់ជូនដោយអ្នកឯកទេស (ដែលត្រូវទទួលបានការអនុញ្ញាតជាមុនពីយើងខ្ញុំ)។

## តារាងអត្ថប្រយោជន៍សុខភាពធ្មេញឆ្នាំ 2024

| កូដ | ការពិពណ៌នា | អ្នកបង់ប្រាក់ |
|---|---|---|
| D0100-D0999 | I. ការធ្វើរោគវិនិច្ឆ័យ - មិនត្រូវបានធានារ៉ាប់រងនោះទេ | |
| D1000-D1999 | II. ការបង្ការជំងឺ - មិនត្រូវបានធានារ៉ាប់រងនោះទេ | |
| D2000-D2999 | III. ការស្តារឱ្យដូចដើមវិញ | |
| • ***ការស្រោបធ្មេញទាមទារឱ្យមានការអនុញ្ញាតជាមុន***<br>• *ការស្រោបធ្មេញត្រូវបានដាក់កម្រិតត្រឹមចំនួនពីរធ្មេញក្នុងមួយឆ្នាំតាមប្រតិទិនក្នុងមួយអ្នកជំងឺ*<br>• *រួមបញ្ចូលទាំងការដុសឱ្យរលោង គ្រឿងបិទឬតភ្ជាប់ធ្មេញទាំងអស់ ការស្រោបបណ្តោះអាសន្នដោយប្រយោល ជាតបណ្តូលធ្មេញ ឧបករណ៍ពត់ក្រាសធ្មេញ និងវិធីព្យាបាលលាងសម្អាតដោយអាស៊ីត។*<br>• *ការដាក់ជំនួសនូវគម្របបណ្តូលធ្មេញ តម្រូវឱ្យមានការស្តារសភាពធ្មេញឱ្យដូចដើមវិញដែលមានស្រាប់រហូតដល់អាយុ 5+ ឡើងទៅ។*<br>• *គម្របស្រោបបណ្តូលធ្មេញ/ធ្មេញដាក់ ដែលមានម៉ាកយីហោ ដែលធ្វើឡើងក្នុងការិយាល័យ ឬធ្វើឡើងក្នុងមន្ទីរពិសោធន៍ ដែលបង្កើតឱ្យមានឡើងតាមបច្ចេកទេសឯកទេស ឬវត្ថុធាតុដែលប្រើគឺជាវត្ថុធាតុដែលដំឡើងគុណភាព។ ទន្តពេទ្យដែលចូលរួមក្នុងគម្រោងអាចនឹងយកថ្លៃសេវាបន្ថែមមិនលើសពី $325.00 នោះទេ បន្ថែមពីលើការបង់ថ្លៃរួមដែលបានរាយបញ្ជី។*<br>• *វីមធ្មេញដែលធ្វើពីប៉សឺឡែនគឺជាជម្រើសសម្រាប់លម្អឱ្យស្អាត។ ទន្តពេទ្យដែលចូលរួមក្នុងគម្រោងបានយល់ព្រមយកថ្លៃសេវាច្រើនបំផុត $75.00 សម្រាប់ប៉សឺឡែន។* | | |
| D2720 | ការស្រោបបណ្តូលធ្មេញ - ជ័រលាយជាមួយលោហៈមានតម្លៃខ្ពស់ | មិនគិតថ្លៃ |
| D2722 | ការស្រោបបណ្តូលធ្មេញ - ជ័រលាយជាមួយលោហៈមានតម្លៃ | មិនគិតថ្លៃ |
| D2750 | ការស្រោបបណ្តូលធ្មេញ - ប៉សឺឡែនរំលាយបញ្ចូលជាមួយលោហៈមានតម្លៃខ្ពស់ | មិនគិតថ្លៃ |

| កូដ | ការពិពណ៌នា | អ្នកបង់ប្រាក់ |
|---|---|---|
| D2752 | ការស្រោបបណ្តូលធ្មេញ - ប៉សឺឡែនរំលាយបញ្ចូលជាមួយលោហៈមានតម្លៃ | មិនគិតថ្លៃ |
| D2790 | ការស្រោបបណ្តូលធ្មេញ - ស្រោបពេញដោយលោហៈមានតម្លៃខ្ពស់ | មិនគិតថ្លៃ |
| D2792 | ការស្រោបបណ្តូលធ្មេញ - ស្រោបពេញដោយលោហៈមានតម្លៃ | មិនគិតថ្លៃ |
| D3000-D3999 | IV. ទន្តពេទ្យឯកទេសជំងឺបណ្តូលធ្មេញ - មិនត្រូវបានធានារ៉ាប់រងទេ | |
| D4000-D4999 | V. ទន្តពេទ្យឯកទេសជំងឺអញ្ចាញធ្មេញ - មិនត្រូវបានធានារ៉ាប់រងទេ | |
| D5000-D5899 | VI. សរីរាង្គសិប្បនិមិត្តទាក់ទងនឹងធ្មេញ (អាចដោះចេញបាន) | |

- *ការធ្វើតល់ធ្មេញឡើងវិញត្រូវបានដាក់កម្រិតត្រឹមម្តងក្នុងមួយឆ្នាំតាមប្រតិទិន ហើយមិនត្រូវបានរ៉ាប់រងនោះទេក្នុងរយៈពេលប្រាំមួយខែនៃការប្តូរលើកដំបូង។*
- *ការប្តូរធ្មេញពាក់ពេញ ឬមិនពេញក្រាសតម្រូវឱ្យមានធ្មេញពាក់ដែលមានស្រាប់រហូតដល់អាយុ 5+ ឡើងទៅ។*

| កូដ | ការពិពណ៌នា | អ្នកបង់ប្រាក់ |
|---|---|---|
| D5670 | ជំនួសធ្មេញ និងជ័រអាគ្រីលីកទាំងអស់នៅលើគ្រោងស្រោបដែលធ្វើពីលោហៈ (ថ្គាមលើ) | មិនគិតថ្លៃ |
| D5671 | ជំនួសធ្មេញនិងជ័រអាគ្រីលីកទាំងអស់នៅលើគ្រោងស្រោបដែលធ្វើពីលោហៈ ថ្គាមក្រោម | មិនគិតថ្លៃ |
| D5710 | ការជួសជុលក្រាសធ្មេញពេញលេញនៃឆ្អឹងថ្គាមលើឡើងវិញ | មិនគិតថ្លៃ |
| D5711 | ការជួសជុលក្រាសធ្មេញពាក់នៃឆ្អឹងថ្គាមក្រោមឡើងវិញ | មិនគិតថ្លៃ |
| D5720 | ការជួសជុលក្រាសធ្មេញពាក់មិនពេញនៃឆ្អឹងថ្គាមលើឡើងវិញ | មិនគិតថ្លៃ |
| D5721 | ការជួសជុលក្រាសធ្មេញពាក់មិនពេញនៃឆ្អឹងថ្គាមក្រោម | មិនគិតថ្លៃ |
| D5900-D5999 | VII. ធ្មេញពាក់ថ្គាមខាងមុខ – មិនត្រូវបានធានារ៉ាប់រងទេ | |
| D6000-D6199 | VIII. សេវាដាំបង្គោលធ្មេញ – មិនត្រូវបានរ៉ាប់រងទេ | |
| D6200-D6999 | IX. សរីរាង្គសិប្បនិមិត្តទាក់ទងនឹងធ្មេញ ដោះចេញមិនបាន (ដែកតម្រង់ធ្មេញនីមួយៗ និងធ្មេញដាក់នីមួយៗបង្កើតបានជាឯកតាក្នុងធ្មេញពាក់ដែលមិនពេញក្រាស ដែលដោះចេញមិនបាន [ស្ពានធ្មេញ]) | |

- *ធ្មេញដាក់ត្រូវបានដាក់កម្រិតត្រឹមតែម្តងក្នុងមួយធ្មេញរាល់ពេលប្រាំឆ្នាំតាមប្រតិទិន។*
- *ការជំនួសធ្មេញដាក់តម្រូវឱ្យមានស្ពានធ្មេញស្រាប់ដល់ទៅអាយុ 5+ ឆ្នាំឡើងទៅ។*
- *ធ្មេញដាក់ ដែលមានម៉ាកយីហោ ដែលធ្វើឡើងក្នុងការិយាល័យ ឬធ្វើឡើងក្នុងមន្ទីរពិសោធន៍ ដែលបង្កើតឱ្យមានឡើងតាមបច្ចេកទេសឯកទេស ឬវត្ថុធាតុដែលប្រើគឺជាវត្ថុធាតុដែលដំឡើងគុណភាព។ ទន្តពេទ្យដែលចូលរួមក្នុងគម្រោងអាចនឹងយកថ្លៃសេវាបន្ថែម មិនលើសពី $325.00 នោះទេ បន្ថែមពីលើការបង់ថ្លៃរួមដែលបានរាយបញ្ជី។*

| កូដ | ការពិពណ៌នា | អ្នកបង់ប្រាក់ |
|---|---|---|
| • *ប៉ាសឺឡែនត្រូវបានចាត់ទុកថាជាការដំឡើងគុណភាពវត្ថុធាតុដោយមានការគិតថ្លៃសេវាបន្ថែមច្រើនបំផុតដល់អ្នកចុះឈ្មោះចំនួន $150.00 ក្នុងមួយថ្គាម។*<br>• *រីមធ្មេញដែលធ្វើពីប៉ាសឺឡែនគឺជាជម្រើសសម្រាប់លម្អឱ្យស្អាត។ ទន្តពេទ្យដែលចូលរួមក្នុងគម្រោងបានយល់ព្រមយកថ្លៃសេវាច្រើនបំផុត $75.00 សម្រាប់ប៉ាសឺឡែន។* | | |
| D6240 | ធ្មេញដាក់ - សារធាតុប៉ាសឺឡែនរំលាយជាមួយលោហ:មានតម្លៃខ្ពស់ | មិនគិតថ្លៃ |
| D6242 | ធ្មេញដាក់ - ប៉ារសឺឡែនរំលាយជាមួយលោហ:មានតម្លៃ | មិនគិតថ្លៃ |
| D6250 | ធ្មេញដាក់ - ជ័រជាមួយលោហ:មានតម្លៃខ្ពស់ | មិនគិតថ្លៃ |
| D6252 | ធ្មេញដាក់ - ជ័រជាមួយលោហ:មានតម្លៃ | មិនគិតថ្លៃ |
| D7000-D7999 | X. ការវះកាត់មាត់ និងថ្គាមមុខ – មិនត្រូវបានធានារ៉ាប់រងនោះទេ | |
| D8000-D8999 | XI. ការកែតម្រូវធ្មេញដែលដុះខុសកន្លែង– មិនត្រូវបានរ៉ាប់រងទេ | |
| D9000-D9999 | XII. សេវាកម្មទូទៅបន្ទាប់បន្សំ – មិនត្រូវបានធានារ៉ាប់រងនោះទេ | |

**ការដាក់កម្រិត៖**

1. ភាពញឹកញាប់នៃអត្ថប្រយោជន៍ជាក់លាក់មួយចំនួនត្រូវបានដាក់កម្រិត។ ការដាក់កម្រិតកំណត់ចំពោះភាពញឹកញាប់ត្រូវបានចុះបញ្ជីក្នុងតារាងអត្ថប្រយោជន៍ខាងលើ។
2. ទន្តពេទ្យដែលចូលរួមក្នុងគម្រោងអាចផ្តល់សេវាកម្ម ដែលប្រើឈ្មោះម៉ាក ឬយីហោដោយមានតម្លៃបន្ថែម។ សមាជិកត្រូវតែទទួលបានការផ្តល់ជូនអត្ថប្រយោជន៍គម្រោងនៃការស្រោបបណ្តូលធ្មេញ/ធ្មេញដាក់ដែលធ្វើឡើងក្នុងមន្ទីរពិសោធន៍ប្រកបដោយគុណភាពខ្ពស់ ដែលអាចរួមមាន៖ ប៉ាសឺឡែន/សេរ៉ាមិក ប៉ាសឺឡែនជាមួយនឹងលោហ:បាត គុណភាពខ្ពស់ និងគុណភាពខ្ពស់ខ្លាំង។ ប្រសិនបើសមាជិកជ្រើសរើសជម្រើសជំនួសនៃការដំឡើងគុណភាពវត្ថុធាតុ (គម្របស្រោបបណ្តូលធ្មេញ/ធ្មេញដាក់ ដែលមានម៉ាកយីហោ ដែលធ្វើឡើងក្នុងការិយាល័យ ឬធ្វើឡើងក្នុងមន្ទីរពិសោធន៍ ដែលបង្កើតឱ្យមានឡើងតាមបច្ចេកទេស ឬវត្ថុធាតុឯកទេស រួមមានជាអាទិ៍៖ Captek, Procera, Lava, Empress និង Cerec) ទន្តពេទ្យដែលចូលរួមក្នុងគម្រោងអាចនឹងគិតថ្លៃសេវាបន្ថែម មិនលើសពី $325.00 នោះទេ បន្ថែមពីលើចំណែកថ្លៃចំណាយដែលត្រូវអនុវត្ត។ សូមទាក់ទងសេវាបម្រើសមាជិកតាមលេខទូរសព្ទនៅលើបណ្ណសម្គាល់សមាជិករបស់អ្នក ប្រសិនបើអ្នកមានសំណួរអំពីថ្លៃសេវាបន្ថែម ឬសេវាដែលមានម៉ាកយីហោ។

**ការលើកលែង៖**

1. នីតិវិធីព្យាបាលណាមួយ ដែលមិនត្រូវបានរាយឈ្មោះជាក់លាក់ក្នុងតារាងអត្ថប្រយោជន៍ខាងលើ។ នីតិវិធីព្យាបាលធ្មេញដែលបានចុះបញ្ជី ដែលមិនត្រូវបានរ៉ាប់រងនៅក្រោមគម្រោងរបស់យើង អាចជាអត្ថប្រយោជន៍ ដែលមានការរ៉ាប់រងនៅក្រោមអត្ថប្រយោជន៍ថ្នាក់រដ្ឋរបស់ Denti-Cal សម្រាប់សមាជិក។ សូមពិនិត្យមើលអត្ថប្រយោជន៍ដែលមានការធានារ៉ាប់រងនៅក្រោមគម្រោង Denti-Cal ផងដែរ។

2. នីតិវិធីព្យាបាលណាមួយ ដែលតាមយោបល់ប្រកបដោយវិជ្ជាជីវៈរបស់ទន្តពេទ្យដែលមានកិច្ចសន្យាៈ
    - មានការព្យាករណ៍មិនល្អចំពោះលទ្ធផលប្រកបដោយជោគជ័យ និងអាយុកាលសមរម្យ ដោយផ្អែកលើស្ថានភាពនៃធ្មេញមួយ ឬធ្មេញច្រើន និង/ឬគ្រោងដែលនៅជុំវិញ ឬ
    - ផ្ទុយគ្នាជាមួយនឹងស្តង់ដារដែលបានទទួលយកជាទូទៅសម្រាប់សុខភាពធ្មេញ។
3. សេវាកម្មសម្រាប់តែគោលបំណងកែសម្ផស្សប៉ុណ្ណោះ ឬសម្រាប់តែស្ថានភាពដែលកើតចេញពីការខូចទ្រង់ទ្រាយពីលក្ខណៈតំណពូជ ឬពេលលូតលាស់ធំឡើង ដូចជាក្រអូមមាត់ឆែប ទម្រង់ខុសប្រក្រតីនៃថ្គាមលើនិងថ្គាមក្រោម ធ្មេញដែលមិនដុះពីកំណើត និងធ្មេញដែលប្រេពណ៌ ឬខ្វះស្រទាប់ខាងក្នុង លើកលែងតែសម្រាប់ការព្យាបាលកុមារទើបកើត ដែលខូចទ្រង់ទ្រាយពីកំណើត ឬភាពមិនប្រក្រតីពីកំណើតប៉ុណ្ណោះ។
4. ការស្រោបបណ្តូលធ្មេញដោយប៉សឺឡែន ប៉សឺឡែនលាយជាមួយនឹងលោហៈ លោហៈឬជ័រដែលជាការស្រោបបណ្តូលធ្មេញដោយប្រភេទលោហៈ និងក្រាសធ្មេញពាក់មិនពេញដែលដោះចេញមិនបាន (ស្ពានធ្មេញ) សម្រាប់កុមារដែលមានអាយុ 16 ឆ្នាំ។
5. ឧបករណ៍ដែលបាត់ ឬត្រូវគេលួច រួមមានជាអាទិ៍ ក្រាសធ្មេញពាក់ពេញឬមិនពេញ ឬប្រដាប់ស្រោបបណ្តូលធ្មេញ។
6. ដំណើរការ ឧបករណ៍ ឬការស្តារមុខងារឡើងវិញ ប្រសិនបើគោលបំណងគឺផ្លាស់ប្តូរទំហំបញ្ឈរ ឬធ្វើរោគវិនិច្ឆ័យ ឬព្យាបាលលក្ខខណ្ឌមិនប្រក្រតីនៃមុខងារសន្លាក់ឆ្អឹងចង្កា (TMJ)។
7. លោហៈធាតុមានតម្លៃសម្រាប់ឧបករណ៍ដែលដោះចេញបាន បាតទន់ជាអចិន្ត្រៃយ៍ ឬបាតលោហធាតុសម្រាប់ធ្មេញពាក់ពេញក្រាស ធ្មេញពាក់ធ្វើពីប៉សឺឡែន ជើងចាប់ភ្ជាប់ផ្នែកដែលដោះចេញបាន ឬក្រាសធ្មេញពាក់មិនពេញដែលចាប់ជាប់នៅនឹងកន្លែង (ការប៉ះផ្ទៃខាងលើ ការប្តូរធ្មេញ និងឧបករណ៍ដែលពាក់ព័ន្ធនឹងធ្មេញ) និងការកែតម្រូវឱ្យមានលក្ខណៈផ្ទាល់ខ្លួន និងការបង្កើតលក្ខណៈរូបរាងក្រាសធ្មេញពាក់ពេញ ឬមិនពេញ។
8. ឧបករណ៍ដែលគាំទ្រដល់ការដាក់ដាំធ្មេញ និងឧបករណ៍ភ្ជាប់ ការប្តូរការដាក់ដាំបង្គោលធ្មេញ ការថែទាំ ការដកចេញ និងសេវាកម្មផ្សេងទៀតទាំងអស់ដែលទាក់ទងនឹងការដាំបង្គោលធ្មេញ។
9. ការពិគ្រោះយោបល់សម្រាប់អត្ថប្រយោជន៍ដែលមិនត្រូវបានធានារ៉ាប់រង។
10. សេវាទន្តសាស្ត្រដែលទទួលបានពីមណ្ឌលថែទាំសុខភាពធ្មេញណាមួយជាជាងទន្តពេទ្យក្នុងបណ្តាញដែលបានចាត់តាំង អ្នកឯកទេសខាងធ្មេញដែលមានការអនុញ្ញាតជាមុន លើកលែងតែសេវាសុខភាពធ្មេញក្នុងភាពអាសន្ន?
11. សេវាកម្ម ឬសម្ភារផ្គត់ផ្គង់ ដែលត្រូវបានធានារ៉ាប់រងក្រោមកម្មវិធីមន្ទីរពេទ្យ ការវះកាត់/វេជ្ជសាស្ត្រ (រួមទាំង Medicare Advantage) ឬកម្មវិធីឱសថមានវេជ្ជបញ្ជា។
12. ថ្លៃចំណាយលើសុខភាពធ្មេញ ដែលកើតមានពាក់ព័ន្ធនឹងនីតិវិធីព្យាបាលធ្មេញ ដែលបានចាប់ផ្តើមឡើងមុនពេលសមាជិកមានសិទ្ធិទទួលបានជាមួយនឹងគម្រោងរបស់យើង។ ឧទាហរណ៍ដូចជាៈ ធ្មេញដែលបានរៀបចំសម្រាប់ការស្រោប ការព្យាបាលរន្ធឬសធ្មេញដែលកំពុងដំណើរការ ក្រាសធ្មេញពាក់ពេញឬមិនពេញ ដែលពុម្ពធ្មេញបានយកធ្វើជាគំរូ។
13. ការព្យាបាល ឬឧបករណ៍ដែលត្រូវបានផ្តល់ដោយទន្តពេទ្យ ដែលឯកទេសរបស់ពួកគេគឺខាងសេវាកម្មធ្មេញសិប្បនិមិត្ត